ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Royaume du Cambodge**
**Nation Religion Roi**

**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIG
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 11 / 2009
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ ៖ 002/19-09-2007-អ.វ.ត.ក. - ក.ស.ច.ស.**

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

កាលបរិច្ឆេទ៖ ២៥ ខែវិច្ឆិកា ឆ្នាំ២០០៩

ភាសាដើម៖ ខ្មែរ /អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ៖ សម្ងាត់

សាធារណៈ
PUBLIC
13/01/2010

# ដីកាសម្រេចលើសំណើសុំបង្កើតវិធានការនីតិវិធីជាក់លាក់

**សហព្រះរាជអាជ្ញា**

អ្នកស្រី ជា លាង
លោក William SMITH

**ជនត្រូវចោទ**

នួន ជា ខៀវ សំផន អៀង សារី
អៀង ធីរិទ្ធ កាំង ហ្គេក អ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ចាន់ឌី
ឡោ ជុនធី
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ីន សុវន
Silke STUDZINSKY
Phillipe CANONNE
Marie Guiraud
Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen

**មេធាវីការពារក្តី**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សុវាន
Jacques VERGES
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARES

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)

បានឃើញការបន្តការស៊ើបសួរលើឈ្មោះ **នួន ជា** និង **ជនផ្សេងទៀត** ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើ**បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៣៩(៤)(ក) និងវិធាន ៦៦ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ (“វិធានផ្ទៃក្នុង”)

បានឃើញសំណើរបស់សហមេធាវីការពារក្តី នួន ជា សុំបង្កើតវិធានការនីតិវិធីជាក់លាក់ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ (D235)

បានឃើញសំណើរបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ សុំបន្ថែមពេលវេលានៅពេលបញ្ចប់ការស៊ើបសួរ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ (D237)

បានឃើញពាក្យសុំរបស់សហមេធាវីការពារក្តី អៀង សារី ស្នើសុំចូលរួមជាមួយសំណើរបស់ នួន ជា ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ (D235/1)

## ការរំលឹកឡើងវិញពីនីតិវិធី និងសេចក្តីសំអាងរបស់ភាគី

១. នៅក្នុងការដាក់ឯកសារមួយ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ក្រុមមេធាវីការពារក្តី នួន ជា (“មេធាវីការពារក្តី”) បានដាក់សំណើមួយសុំបង្កើតវិធានការនីតិវិធីជាក់លាក់ (បន្ទាប់មកហៅ

ថា "សំណើ") ដោយបានផ្អែកលើវិធានផ្ទៃក្នុង ៦៦ ដែលក្នុងសំណើនោះ បានស្នើឱ្យសហចៅក្រមស៊ើបអង្កេត ៖

*"ជូនដំណឹងដល់ភាគីទាំងអស់ឱ្យបានឆាប់រហ័សបំផុត តាមតែអាចធ្វើបាន ក្នុងរយៈពេលយ៉ាងយូរបំផុតពីរខែ មុនពេលដាក់ការជូនដំណឹងពីកាលបរិច្ឆេទពិតប្រាកដ ដែល ក.ស.ច.ស មានផែនការដាក់ការជូនដំណឹង អនុលោមតាមវិធាន ៦៦។*

*ដាក់បញ្ចូលលទ្ធផលថ្មីទាំងអស់នៃការស៊ើបសួរទៅក្នុងសំណុំរឿង ក្នុងរយៈពេលយ៉ាងយូរបំផុតពីរខែ មុនពេលដាក់ការជូនដំណឹងអនុលោមតាមវិធាន ៦៦។ ក្របខណ្ឌពេលវេលានេះ គឺសំខាន់ចាំបាច់ ដើម្បីធានាដល់ការចូលរួមនៅក្នុងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពពីសំណាក់មេធាវីការពារក្តី។*

*សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់សម្រេចទាំងអស់ ក្នុងរយៈពេលយ៉ាងយូរបំផុតពីរខែ មុនពេលដាក់ការជូនដំណឹង អនុលោមតាមវិធាន ៦៦។ ក្របខណ្ឌពេលវេលានេះ គឺសំខាន់ចាំបាច់ ដើម្បីធានាដល់ការចូលរួមនៅក្នុងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពពីសំណាក់មេធាវីការពារក្តី។ និង*

*ឆ្លើយតបចំពោះសំណើនេះក្នុងរយៈពេលពីរសប្តាហ៍ បន្ទាប់ពីបានដាក់"*[1]។

២. មេធាវីការពារក្តីបានរំលឹកថា យោងតាមវិធានផ្ទៃក្នុង និងកិច្ចព្រមព្រៀងឆ្នាំ២០០៤ ជនត្រូវចោទ នួន ជា មានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀម និងរៀបចំការការពារខ្លួនគាត់ ហើយថា "*ក្នុងចំណោម បញ្ហាដទៃទៀត ភាពគ្មានមន្ទិលសង្ស័យផ្នែកច្បាប់ និងតម្លាភាពរបស់ដំណើរការនីតិវិធីមានសារៈសំខាន់ជាទីបំផុតនៅទូទាំងដំណើរការនីតិវិធី*"។

៣. នៅក្នុងសំណើរបស់ពួកគាត់ មេធាវីការពារក្តីលើកទឡ្ហីករណ៍ថា "*មានតែបង្កើតនូវវិធានការទាំងនេះទេ*" ដែលនឹងអាចឱ្យមេធាវីការពារក្តីយកវិធានការដាក់លាក់ទាំងនេះដើម្បីការពារ "*សិទ្ធិ*

---

[1] D235 សំណើសុំបង្កើតវិធានការនីតិវិធីជាក់លាក់ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៨។

*ក្នុងការទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌របស់ នួន ជា"* ហើយបានគូសបញ្ជាក់បន្ថែមទៀតអំពីបញ្ហានីតិវិធី ទាក់ទិនទៅនឹងការស៊ើបសួរ ដែលខ្លួនយល់ថា *"អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរ"* ដល់សិទ្ធិទាំងនេះ ។

៤. នៅថ្ងៃទី១១ ខែវិច្ឆិកា មេធាវីការពារក្ដី អៀង ធីរិទ្ធ ក៏បានដាក់សំណើមួយផងដែរ ទាក់ទិនទៅនឹងបញ្ហានៃការជូនដំណឹងក្រោមវិធាន ៦៦ ដែលមានការគាំទ្រនូវសំណើនោះ ដោយ នួន ជា ប៉ុន្តែទម្រង់នៃសំណូមពរខុសគ្នា ៖

> *"មេធាវីការពារក្ដីស្នើឱ្យ ក.ស.ច.ស ៖ (i) ជូនដំណឹងដល់ភាគីទាំងអស់អំពីកាលបរិច្ឆេទពិតប្រាកដនៃការជូនដំណឹងរបស់ខ្លួន (ii) ដាក់ចូលបន្ថែមនូវព័ត៌មានថ្មីៗដែលប្រមូលបានទៅក្នុងសំណុំរឿង នៅពេលវេលាដ៏សមគួរបំផុត និង (iii) ពន្យារពេលវេលាកំណត់ចំនួនដប់ប្រាំ (១៥)ថ្ងៃ ដែលបានផ្ដល់ឱ្យនៅក្នុងវិធានផ្ទៃក្នុង ៦៦(១) ឱ្យបានសែសិបប្រាំ (៤៥)ថ្ងៃ"*។

៥. ចុងក្រោយ ក្នុងការចូលរួមជាមួយសំណើរបស់ នួន ជា មេធាវីការពារក្ដី អៀង សារី បានបញ្ជាក់ថា ខ្លួន *"បានអនុម័តយកដោយគ្មានខដាក់លក្ខខណ្ឌនូវទឡ្ហីករណ៍អង្គហេតុ និងអង្គច្បាប់ទាំងអស់ ដែលបានលើកឡើងដោយមេធាវីការក្ដី នួន ជា។ ពាក្យសុំចូលរួមនេះ មានសារៈសំខាន់ក្នុងការជៀសវាងនូវភាពអយុត្តិធម៌ជាក់ស្ដែង ចំពោះជនត្រូវចោទទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២ ដូចដែលបានរៀបរាប់នៅក្នុងសំណើសុំ"*។

## សំអាងហេតុនៃសេចក្ដីសម្រេច

៦. សំណើរបស់ នួន ជា ដែលត្រូវបានចូលរួមដោយមេធាវីការពារក្ដី អៀង សារី មានទម្រង់ជាសំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ក្នុងទម្រង់ជាសំណើសុំបំពេញកិច្ចស៊ើបសួរ ៖ សហចៅក្រមស៊ើបអង្កេត ត្រូវបានស្នើឱ្យជូនដំណឹងរយៈពេលពីរខែ អំពីគោលបំណងរបស់ខ្លួនក្នុងការដាក់ការជូនដំណឹងក្រោមវិធាន ៦៦ ដែលក្នុងអំឡុងរយៈពេលនេះ មិនមានភស្តុតាងបន្ថែមណា

មួយត្រូវបានដាក់ទៅក្នុងសំណុំរឿងឡើយ។ ហើយត្រូវឆ្លើយតបទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរទាំងអស់របស់ភាគី ដែលមិនទាន់បានសម្រេច មុនពេលការជូនដំណឹងជាមុននេះ"។

៧. សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា បញ្ហាទាំងអស់នេះត្រូវបានចែងយ៉ាងច្បាស់ និងពេញលេញនៅក្នុងវិធាន ៦៦ គោលបំណងយ៉ាងច្បាស់លាស់នៃវិធាននេះ គឺដើម្បីឲ្យមានការជូនដំណឹងចំពោះរឿងដែលថា សហចៅក្រមស៊ើបអង្កេតយល់ឃើញថាការស៊ើបសួរបានបញ្ចប់ ដើម្បីអនុញ្ញាតឲ្យភាគីទាំងអស់ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀត។

៨. ទាក់ទិនទៅនឹងបញ្ហានេះ ដូចដែលមេធាវីការពារក្តីបានគូសបញ្ជាក់ ការពង្រីកវិធាន ៦៦ ដើម្បីអនុញ្ញាតឲ្យគ្រប់ភាគី *ទាំងអស់* អាចដាក់សេចក្តីសន្និដ្ឋាន ត្រូវបានអនុម័តដោយចៅក្រមនៅក្នុងកិច្ចប្រជុំពេញអង្គ ក្នុងគោលបំណងដើម្បីពង្រឹងសមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នាឲ្យកាន់តែប្រសើរជាងអ្វីដែលបានចែងនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាជាធរមាន។

៩. លើសពីនេះទៀត មិនមានភស្តុតាងបន្ថែមណាមួយអាចត្រូវបានដាក់នៅក្នុងសំណុំរឿងឡើយ បន្ទាប់ពីមានការជូនដំណឹងក្រោមវិធាន ៦៦។ តាមពិត ទោះបីជាការជូនដំណឹងនៃវិធាន ៦៦ ត្រូវបានធ្វើឡើងហើយក៏ដោយ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចថា ខ្លួនចាំបាច់ត្រូវដាក់ភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកបន្ថែមទៀតទៅក្នុងសំណុំរឿង ពួកគាត់នឹងត្រូវបានតម្រូវឲ្យជូនដំណឹងជាថ្មីម្តងទៀត ក្រោមវិធាន ៦៦ ដដែល។

១០. ចំពោះសំណើសុំឲ្យសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់បានសម្រេចទាំងអស់ មុនពេលដាក់ការជូនដំណឹងក្រោមវិធាន ៦៦ វិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់លាស់ថា សំណើទាំងអស់ *"ដែលបានដាក់ជូនតាំងពីពេលដំបូងនៃការស៊ើបសួរ ដែលសហចៅក្រមស៊ើបអង្កេតមិនទាន់បានសម្រេចនៅឡើយ"* អាចត្រូវបានគេសម្រេចទៅលើសំណើទាំងនោះ យ៉ាងយូរបំផុត នៅពេលដែលមានការឆ្លើយតបទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ដែលបានដាក់ក្នុងអំឡុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការជូនដំណឹងក្រោមវិធាន ៦៦។

១១. ពិតណាស់ គ្រប់ចម្លើយតបទាំងអស់ត្រូវតែធ្វើឡើងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយសហចៅក្រមស៊ើបអង្កេតបានសង្កត់បញ្ជាក់ជាថ្មីទៀតថា ដើម្បីជាផលប្រយោជន៍នៃប្រសិទ្ធិភាពដំណើរការនីតិវិធី សហចៅក្រមស៊ើបអង្កេតកំពុងតែខិតខំប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងសំណើទាំងអស់ដែលមិនទាន់បានសម្រេចនៅពេលនេះ ដោយមិនរង់ចាំបញ្ចប់កិច្ចស៊ើបសួរឡើយ[2]។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីជាក់ស្តែងមួយចំនួន សេចក្តីសម្រេចលើការ ចាំបាច់ក្នុងបំពេញកិច្ចស៊ើបសួរណាមួយដែលបានស្នើសុំនោះ អាចត្រូវធ្វើឡើងបានតែនៅពេលដែលប្រភពព័ត៌មាន ឬវិធីសាស្រ្តនៃការស៊ើបសួរទាំងអស់ផ្សេងៗទៀតត្រូវបានស៊ើប អង្កេតយ៉ាងពេញលេញប៉ុណ្ណោះ ដូច្នេះសេចក្តីសម្រេចមិនអាចត្រូវបានធ្វើឡើងឲ្យបានឆាប់រហ័សពេកនោះទេ។

១២. លើសពីនេះទៀត គួរត្រូវគេរំលឹកថា ដើម្បីរក្សាការពារសិទ្ធិរបស់ភាគីទាំងអស់នៅកម្រិតមួយខ្ពស់បំផុត ក្នុងខែឧសភា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីទាំងអស់យ៉ាងច្បាស់លាស់តាមដែរអាចធ្វើទៅបាន អំពីកាលបរិច្ឆេទដែលត្រូវបានប៉ាន់ប្រមាណនៃការបញ្ចប់កិច្ចស៊ើបសួរនៅដំណាច់ឆ្នាំនេះ និងបានបញ្ជាក់អំពីគោលបំណងនេះនៅក្នុងឱកាសមួយចំនួន ដែលនាពេលថ្មីៗបំផុតនេះ គោលបំណងនេះត្រូវបានបញ្ជាក់នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ច.ស នៅថ្ងៃព្រហស្បតិ៍ ទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩។

[2] D221/1 **ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងលិខិតរបស់មេធាវី នួន ជា ស្តីអំពីកង្វះទំនុកចិត្តចំពោះកិច្ចស៊ើបសួរ** ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩។ ចម្លើយតបត្រូវបានធ្វើឡើងនាពេលថ្មីៗនេះ តបទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តីដែលមិនទាន់ត្រូវបានសម្រេចមួយចំនួន ៖ D214/2 **ចម្លើយតបរបស់ សហចៅក្រមស៊ើបអង្កេត ទៅនឹងសំណើរបស់មេធាវី អៀង សារី លើកទី៧ សុំឲ្យបំពេញកិច្ចស៊ើបសួរ** ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩,។ D218/2 **ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹងសំណើរបស់មេធាវី អៀង សារី លើកទី៨ សុំឲ្យបំពេញកិច្ចស៊ើបសួរ** ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩,។ D130/11/2 **ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹងសំណើរបស់មេធាវី នួន ជា លើកទី១៥ សុំឲ្យបំពេញកិច្ចស៊ើបសួរ និងលិខិត ដែលទាក់ទិនមួយចំនួនរបស់មេធាវី អៀង សារី** ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩,។ D140/6 **ចម្លើយ តបរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹងមេធាវី អៀង សារី ស្តីពីសំណើសុំព័ត៌មាន ទាក់ទងនឹងអ្នកជំនាញប្រជាសាស្រ្តកម្ពុជា** ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩, និង D194/2 **ដីកាសម្រេចលើសំណើសុំធ្វើប្រតិចារឹក** ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩,។

១៣. ដូច្នេះ សហចៅក្រមស៊ើបអង្កេត មិនបានឃើញមាននូវចន្លោះប្រហោងណាមួយនៅក្នុងវិធានផ្ទៃក្នុង ទាក់ទិនទៅនឹងការជូនដំណឹងនៃវិធាន ៦៦ ដែលអាចលើកឡើងបាននូវបញ្ហា ទាក់ទងទៅនឹងសិទ្ធិរបស់ជនត្រូវចោទ ក្នុងការចូលរួមនៅក្នុងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពនោះឡើយ ដូច្នេះកិច្ចដែលត្រូវបានស្នើសុំនោះមានយុត្តិកម្មត្រឹមត្រូវ។

១៤. ជាពិសេស ចិរវេលាក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេត ដែលសេចក្តីសម្រេចនោះត្រូវបានធ្វើឡើងក្នុងក្របខណ្ឌវិធាន ៦៦ គឺដូចគ្នាទៅនឹងចិរវេលាក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចផ្សេងៗទៀតទាំងអស់របស់សហចៅក្រមស៊ើបអង្កេតដែរ ដូច្នេះមិនអាចត្រូវបានគេគិតថាមិនមានយុត្តិធម៌ចំពោះមេធាវីការពារក្តីឡើយ នៅក្នុងករណីនេះ។

១៥. ទាក់ទិនទៅនឹងបញ្ហា ដែលត្រូវបានលើកឡើងជាពិសេស ដោយមេធាវីការពារក្តី អៀង ធីរិទ្ធ ថាតើរយៈពេល ១៥ថ្ងៃ ដែលត្រូវបានផ្តល់ជូននៅក្នុងវិធាន គ្រប់គ្រាន់ឬយ៉ាងណានោះ ដោយពិចារណាទៅលើកាលៈទេសៈនៃរឿងក្តី និងសេចក្តីត្រូវការក្នុងការបកប្រែ សហចៅក្រមស៊ើបអង្កេតកត់សំគាល់ថា ចិរវេលានេះគឺត្រូវគ្នាជាមួយនឹងចិរវេលា ដែលបានចែងនៅក្នុងមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលជនត្រូវចោទស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន។ តាមពិត ការណ៍ដែលចិរវេលានេះខ្លី ក្នុងករណីដែលជនត្រូវចោទកំពុងជាប់ឃុំខ្លួន បានបង្ហាញអំពីគោលបំណងរបស់អ្នកតាក់តែងច្បាប់ក្នុងការជៀសវាងនូវការពន្យារពេលហួសប្រមាណក្នុងការបញ្ចប់កិច្ចស៊ើបសួរនៅក្នុងករណីបែបនេះ។

១៦. ទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេត ទទួលស្គាល់ថា ស្ថានភាពនៅ អ.វ.ត.ក អាចមានលក្ខណៈខុសគ្នាពីដំណើរកាធម្មតានៃដំណើរការនីតិវិធីព្រហ្មទណ្ឌកម្ពុជា បើយើងពិនិត្យទៅលើវិសាលភាពនៃការស៊ើបសួរនៅ អ.វ.ត.ក និងការណ៍ដែលថាជនត្រូវចោទត្រូវបានអនុញ្ញាតឲ្យលើកឡើងនូវសំណើបន្ថែមទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា។ ក្នុងករណីដែលមិនមានការណែនាំច្បាស់លាស់នៅក្នុងដំណើរការនីតិវិធីកម្ពុជា ដូច្នេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មានហេតុផលគ្រប់គ្រាន់ដើម្បីកែប្រែពេលវេលាកំណត់ជាធរមាននៅក្នុងករណីនេះ អនុលោមតាមវិធាន ៣៩(៤)(ខ) ដើម្បីបង្កើតឲ្យមាននូវតុល្យភាពសមស្របរវាងសិទ្ធិក្នុង

ការទទួលបានការជំនុំជម្រះទោសឲ្យបានឆាប់រហ័ស និងការអនុវត្តសិទ្ធិរបស់គ្រប់ភាគីទាំងអស់ ប្រកបដោយប្រសិទ្ធភាព ក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀត។

## ហេតុដូច្នេះ

- **សម្រេច បដិសេធ**សំណើរបស់ នួន ជា សុំបង្កើតវិធានការនីតិវិធីបន្ថែម និង
- **សម្រេច** ទទួលស្គាល់សុពលភាពនៃសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទាំងឡាយណាដែលបានដាក់បន្ទាប់ពីពេលវេលាកំណត់រយៈពេលដប់ប្រាំ (១៥)ថ្ងៃ ដូចមានចែងនៅក្នុងវិធាន ៦៦(១) ត្រូវបានផុតរលត់ ដរាបណាសំណើទាំងនោះត្រូវបានដាក់ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងពីសហចៅក្រមស៊ើបអង្កេតអនុលោមតាមអនុវិធាននោះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juges d'instruction

យូ ប៊ុនឡេង

**Marcel LEMONDE**